ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤០៦ អនក្រ.បក

# អនុក្រឹត្យ

ស្ដីពី

## ការកាត់ដីទំហំ ៥៧៦,៣២ ហិកតា នៅស្រុកកោះកុង ខេត្តកោះកុង ចេញពីឧទ្យានជាតិបុទុមសាគរ និងដែនជម្រកសត្វព្រៃតាតៃ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២២៣ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០២៤/១៧ ល.ស ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង
- លិខិតលេខ ០២៦/១៧ ល.ស ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង
- លិខិតលេខ ៧៦៣ ដនស/អសក ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៤០៦៣ កសក ចុះថ្ងៃទី ១២ ខែ ឧសភាឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ ៨៧៤ សជណ ប.ស្ថ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ របស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៥៧៦,៣២ ហិកតា ចេញពីដីឧទ្យានជាតិបុទុមសាគរ និងដែនជម្រកសត្វព្រៃតាតៃដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/១១១៧/១១០៦ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៧ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែងទំហំ ៥០១,២៣ ហិកតា និងផ្ទៃដីទំហំ ៧៥,០៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅស្រុកកោះកុង ខេត្តកោះកុង ក្នុងនោះ

- ផ្ទៃដីសរុបទំហំ ៣៤១,៩៦ **ហិកតា** កាត់ចេញពីដីឧទ្យានជាតិបុទុមសាគរ និងដែនជម្រកសត្វព្រៃតាតៃដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែង ទំហំ ២៩៤,៥៨ ហិកតា និងផ្ទៃដី ទំហំ ៤៧,៣៨ ហិកតា រក្សាទុកជាដី សាធារណៈរបស់រដ្ឋ **ស្ថិតនៅភូមិព្រែកអង្គញ ឃុំត្រពាំងរូង**

- ផ្ទៃដីសរុបទំហំ **២៣៤,៣៦ ហិកតា** កាត់ចេញពី ដីឧទ្យានជាតិបុទុមសាគរ និងដែនជម្រកសត្វព្រៃតាតៃ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ដាំដុះជាក់ស្តែង **ទំហំ ២០៦,៦៥ ហិកតា** និងផ្ទៃដី**ទំហំ ២៧,៧១ ហិកតា** រក្សាទុកជាដី សាធារណៈរបស់រដ្ឋ **ស្ថិតនៅភូមិកោះកុងក្នុង ឃុំត្រពាំងរូង**

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋចំនួន ២២៣ **គ្រួសារ នៅស្រុកកោះកុង ខេត្តកោះកុង** ក្នុងនោះ

-ប្រជាពលរដ្ឋចំនួន **៩៨ គ្រួសារ** នៅភូមិព្រែកអង្គុញ ឃុំត្រពាំងរូង

-ប្រជាពលរដ្ឋចំនួន **១២៥ គ្រួសារ** នៅភូមិកោះកុងក្នុង ឃុំត្រពាំងរូង ។

**មាត្រា ៣** : ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៣២១ ក្បាលដី ស្ថិតនៅស្រុកកោះកុង ខេត្តកោះកុង ក្នុងនោះ

- ក្បាលដីចំនួន **១៥៣ ក្បាលដី** ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ **៩៧ គ្រួសារ** ។ ដោយឡែក ០១ក្បាលដី ជាក្បាលដីមានទំហំធំជាង ១០ ហិកតា អនុញ្ញាតឲ្យចុះបញ្ជីដីធ្លីតាមនីតិវិធីចុះបញ្ជីដាច់ដោយដុំជាក្រោយ និងក្បាលដីចំនួន ១១ ក្បាលដី ជាក្បាលដីគ្មានទិន្នន័យ ប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ដើម្បីគ្រប់គ្រងថែរក្សាការពារជាទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាព ស្ថិតនៅភូមិព្រែកអង្គុញ ឃុំត្រពាំងរូង
- ក្បាលដីសរុបចំនួន ១៦៨ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន **១៦៧ ក្បាលដី** ជូនប្រជាពលរដ្ឋ **១២៥ គ្រួសារ** និងផ្តល់សិទ្ធិជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋចំនួន ០១ ក្បាលដី (ដីសាលារៀន) ។ ដោយឡែកក្បាលដីចំនួន ០៥ ក្បាលដី ជាក្បាលដីគ្មានទិន្នន័យ ប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ដើម្បីគ្រប់គ្រងថែរក្សាការពារជាទ្រព្យសម្បត្តិ រដ្ឋឱ្យមានប្រសិទ្ធភាព ស្ថិតនៅភូមិកោះកុងក្នុង ឃុំត្រពាំងរូង ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុងត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០៦ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០១៧ ស្តីពីការកាត់ដីសរុបទំហំ ៣៤១.៩៦ ហិកតា នៅស្រុកកោះកុង ខេត្តកោះកុង ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

តារាងនិយាមកាចំណុចព្រំដី

Projection : UTM Zone 48N Datum WGS84

| Pt_ID | Easting (m) | Northing (m) | Pt_ID | Easting (m) | Northing (m) | Pt_ID | Easting (m) | Northing (m) |
|---|---|---|---|---|---|---|---|---|
| 1 | 308119 | 1258501 | 57 | 304929 | 1259499 | 113 | 304896 | 1259751 |
| 2 | 308113 | 1258475 | 58 | 304783 | 1259280 | 114 | 304998 | 1259709 |
| 3 | 307918 | 1258481 | 59 | 304600 | 1259407 | 115 | 305324 | 1259558 |
| 4 | 307777 | 1258510 | 60 | 304900 | 1259506 | 116 | 305425 | 1259499 |
| 5 | 307568 | 1258593 | 61 | 304743 | 1259540 | 117 | 305515 | 1259428 |
| 6 | 307150 | 1258750 | 62 | 304537 | 1259668 | 118 | 305708 | 1259191 |
| 7 | 306530 | 1258804 | 63 | 304464 | 1259609 | 119 | 306006 | 1258928 |
| 8 | 306481 | 1258867 | 64 | 304397 | 1259662 | 120 | 306246 | 1258814 |
| 9 | 306301 | 1258987 | 65 | 304336 | 1259590 | 121 | 306389 | 1258678 |
| 10 | 306013 | 1259217 | 66 | 303971 | 1259832 | 122 | 306462 | 1258605 |
| 11 | 306165 | 1259271 | 67 | 304121 | 1260074 | 123 | 306300 | 1258395 |
| 12 | 306274 | 1259243 | 68 | 304031 | 1260106 | 124 | 306490 | 1258394 |
| 13 | 306308 | 1259329 | 69 | 303830 | 1259941 | 125 | 306521 | 1258569 |
| 14 | 306467 | 1259237 | 70 | 303701 | 1260031 | 126 | 306881 | 1258360 |
| 15 | 306618 | 1259084 | 71 | 303637 | 1260075 | 127 | 307167 | 1258163 |
| 16 | 306701 | 1259027 | 72 | 303571 | 1260120 | 128 | 304180 | 1261239 |
| 17 | 306731 | 1259077 | 73 | 303408 | 1260234 | 129 | 304307 | 1260905 |
| 18 | 306953 | 1259023 | 74 | 303482 | 1260296 | 130 | 304419 | 1260954 |
| 19 | 307046 | 1259066 | 75 | 303588 | 1260144 | 131 | 304590 | 1260612 |
| 20 | 307124 | 1259062 | 76 | 303653 | 1260106 | 132 | 304761 | 1260357 |
| 21 | 307435 | 1258905 | 77 | 303816 | 1260214 | 133 | 304716 | 1260305 |
| 22 | 307705 | 1258834 | 78 | 303856 | 1260248 | 134 | 304779 | 1260303 |
| 23 | 307898 | 1258757 | 79 | 303903 | 1260309 | 135 | 304837 | 1260267 |
| 24 | 307861 | 1258652 | 80 | 303798 | 1260360 | 136 | 304942 | 1260218 |
| 25 | 307941 | 1258557 | 81 | 303723 | 1260503 | 137 | 305031 | 1260118 |
| 26 | 308119 | 1258501 | 82 | 303686 | 1260668 | 138 | 305225 | 1260266 |
| 27 | 308253 | 1259169 | 83 | 303677 | 1260798 | 139 | 305286 | 1260208 |
| 28 | 308209 | 1259095 | 84 | 303700 | 1260928 | 140 | 305234 | 1260091 |
| 29 | 308061 | 1259158 | 85 | 303435 | 1261071 | 141 | 305450 | 1260009 |
| 30 | 308133 | 1259286 | 86 | 303492 | 1260924 | 142 | 305633 | 1259864 |
| 31 | 308253 | 1259169 | 87 | 303396 | 1260811 | 143 | 305461 | 1259703 |
| 32 | 307336 | 1258440 | 88 | 303169 | 1260986 | 144 | 305022 | 1259904 |
| 33 | 307690 | 1258316 | 89 | 303090 | 1260921 | 145 | 304656 | 1260077 |
| 34 | 307569 | 1258161 | 90 | 302747 | 1261273 | 146 | 304410 | 1260246 |
| 35 | 307429 | 1258196 | 91 | 302490 | 1261531 | 147 | 304288 | 1260340 |
| 36 | 307449 | 1258311 | 92 | 302251 | 1261353 | 148 | 304221 | 1260422 |
| 37 | 307322 | 1258381 | 93 | 301987 | 1261442 | 149 | 304150 | 1260582 |
| 38 | 307336 | 1258440 | 94 | 302048 | 1261177 | 150 | 304137 | 1260631 |
| 39 | 307167 | 1258163 | 95 | 301645 | 1261456 | 151 | 304156 | 1260827 |
| 40 | 307116 | 1258022 | 96 | 301671 | 1261537 | 152 | 304057 | 1261186 |
| 41 | 306886 | 1258069 | 97 | 301814 | 1261668 | 153 | 304137 | 1261233 |
| 42 | 306798 | 1258034 | 98 | 301780 | 1261760 | 154 | 304180 | 1261239 |
| 43 | 306541 | 1258200 | 99 | 301837 | 1262089 | 155 | 305809 | 1259414 |
| 44 | 306337 | 1258202 | 100 | 302012 | 1262053 | 156 | 305938 | 1259554 |
| 45 | 306258 | 1258257 | 101 | 302322 | 1261846 | 157 | 306008 | 1259510 |
| 46 | 306223 | 1258449 | 102 | 302569 | 1261661 | 158 | 305962 | 1259429 |
| 47 | 305866 | 1258748 | 103 | 302888 | 1261487 | 159 | 306047 | 1259337 |
| 48 | 305834 | 1258831 | 104 | 303580 | 1261309 | 160 | 305941 | 1259269 |
| 49 | 305569 | 1259056 | 105 | 303699 | 1261264 | 161 | 305809 | 1259414 |
| 50 | 305572 | 1259182 | 106 | 303837 | 1261125 | 162 | 304009 | 1261332 |
| 51 | 305465 | 1259156 | 107 | 303880 | 1261037 | 163 | 303892 | 1261432 |
| 52 | 305384 | 1259031 | 108 | 303928 | 1260880 | 164 | 303891 | 1261519 |
| 53 | 305293 | 1259033 | 109 | 303941 | 1260809 | 165 | 303913 | 1261562 |
| 54 | 305392 | 1259234 | 110 | 303966 | 1260376 | 166 | 304129 | 1261350 |
| 55 | 305210 | 1259385 | 111 | 304207 | 1260112 | 167 | 304009 | 1261332 |
| 56 | 304995 | 1259432 | 112 | 304499 | 1259910 | | | |

